ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

ROYAL UNIVERSITY OF LAW AND ECONOMICS

មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង

ជំនាញ : គ្រប់គ្រងធុរៈកិច្ច

ថ្នាក់ : E1MA02


## វប្បធម៌ខ្មែរ សម្រាប់ថ្នាក់សិក្សាមូលដ្ឋាន

បង្រៀនដោយលោកគ្រូ ហ៊ីង គឹមឡេង

## ប្រធានបទ :

# "ពិធីបុណ្យភ្ជុំបិណ្ឌ"


អ្នករៀបរៀង : និត កុសល

អ៊ុង សុខសាធរ៉េមី

អឿន ប៊ុនថន

យឿង មករា

ខេន វណ្ណឌីណា


១១ វិច្ឆិកា ២០១៥

រក្សាសិទ្ធិ

# អារម្ភកថា

ជាបឋម សូមជំរាបសួរដល់ លោកគ្រូអ្នកគ្រូ បងប្អូនសិស្សានុសិស្សទាំងអស់ ជាទីមេត្រី។ ក្នុងឱកាសដ៏ល្អនេះយើងខ្ញុំជាសិស្សនិស្សិត**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** នៃមហាវិទ្យាល័យ វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង ថ្នាក់ E1MA02 មាន សេចក្តី រីករាយ បន្ទាប់ពី លោកគ្រូ **ហ៊ីង តឹមឡេង** ដែលបង្រៀនមុខវិជ្ជា វប្បធម៌ទូទៅ ហើយ លោកគ្រូ ក៏ បានដាក់ ប្រធានបទមួយ ឱ្យពួកយើងយកទៅធ្វើការស្រាវជ្រាវ គឺ **ពិធីបណ្យភ្ជុំបិណ្ឌ** ដែលយើងតែងតែឃើញថា ប្រជាពលរដ្ឋខ្មែរយើង និយមប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ហេតុនេះពួកយើងខ្ញុំបាន ខិតខំស្រាវជ្រាវ ប្រមូលចងក្រង រាល់ឯកសារទាំងឡាយណាដែលជាប់ ទាក់ទងនឹងបុណ្យភ្ជុំបិណ្ឌ។ គោលបំណងសំខាន់ក្នុងប្រធានបទ ពិធីបុណ្យភ្ជុំបិណ្ឌនេះ គឺជួយផ្តល់នូវចំណេះដឹង រឿងរ៉ាវដែលជាប្រវត្តិសាស្ត្រពិត នៃ ពិធីបុណ្យភ្ជុំបិណ្ឌ ជាមួយនឹងគំនិតបណ្តុំសារតី ស្រលាញ់វប្បធម៌ អរិយធម៌ សាសនា ទំនៀមទំម្លាប់ខ្មែរ ហើយត្រូវចេះថែរក្សានូវ ពិធីបុណ្យភ្ជុំបិណ្ឌ ទុករហូតជានិមិត្តរូបនៃប្រពៃណីជាតិខ្មែរ តាំងពីសម័យបូរាណ រហូតមកដល់បច្ចុប្បន្ន និងបន្តទៅអនាគត ដើម្បី ឱ្យកូនចៅខ្មែរជំនាន់ក្រោយស្គាល់ និងធ្វើពិធីបុណ្យភ្ជុំបិណ្ឌជារៀងរាល់ឆ្នាំ។

ជាចុងក្រោយយើងខ្ញុំអ្នករៀបរៀង សូមអរគុណលោកគ្រូ អ្នកគ្រូ សិស្សនិស្សិតទាំងអស់ដែលបានអាន ប្រធាននេះ ហើយរង់ចាំការរិះគល់ក្នុងន័យស្ថាបនា កែលំហ ភាពខ្វះខាត លើក ខុសខាត ដោយប្រការណាមួយក៏សូមអនុគ្រោះ ឬក៏ទាក់ទងមកក្រុមយើងខ្ញុំ ដើម្បីកែតម្រូវ និងសូមជូនពរ ឱ្យមិត្តអ្នកទាំងអស់ជួបតែសេចក្តីសុខ សុខភាព ហើយមានគំនិតជាតិនិយម ស្រលាញ់វប្បធម៌។

ភ្នំពេញថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៥

អ្នករៀបរៀង៖ **និត កុសល អ៊ឹង សុខសាធរ៉េមី សឿន ប៊ុនថន**

**យឿន មករា** និង **ខេន វណ្ណឌីណា**

# មាតិកា


ចំណងជើងអត្ថបទ លេខ ទំព័រ

១.ប្រវត្តិបុណ្យភ្ជុំបិណ្ឌ.....៣
១.១. សាស្ត្រាវិជ្ជាធរ.....៣
១.២. សាស្ត្រាអានិសង្សបិណ្ឌ.....៥
១.៣. គម្ពីរបេតវត្ថុ.....៦
១.៤. តាមប្រវត្តិសាស្ត្រជាតិ.....៧
២. មូលហេតុដែលប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ.....៨
៣. ការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ.....១០
៣.១. បុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ.....១០
៣.២. បរាភវសូត្រ.....១៤
៣.៣. ការបោះបាយបិណ្ឌ.....១៤
៣.៤. ការជូនភ្ជុំខ្សាច់ក្នុងពិធីបុណ្យភ្ជុំបិណ្ឌ.....១៥
៣.៥. ឧទ្ទិសផល និងសែន.....១៦
៣.៦. ពិធីសែន.....១៧
៣.៧. ប្រេត.....១៨
៤. សេចក្តីសន្និដ្ឋាន.....១៨
៤.១. គុណសម្បត្តិ.....១៨
៤.២. គុណវិបត្តិ.....១៩
៥. វាយតម្លៃ.....១៩

## ១. ប្រវត្តិបុណ្យភ្ជុំបិណ្ឌ

ពាក្យថា "ភ្ជុំបិណ្ឌ" មកពីពាក្យ "ភ្ជុំ" រួមគ្នាជាមួយពាក្យ "បិណ្ឌ" ដែលមានន័យថា: ភ្ជុំ គឺជា ការប្រមូលផ្តុំ ឬ ប្រជុំបិណ្ឌ (មកពីភាសាបាលី) ហៅថា "ដុំបាយ" ដូច្នេះយើងអាចសម្គាល់ពាក្យនេះ តាម វិធីងាយបានថា គឺជា "ការប្រជុំ ឬប្រមូលផ្តុំដុំបាយ" (ការពូតដុំ បាយជាដុំៗដែលយើងហៅថា "បាយបិណ្ឌ") ។

តាមដែលបានស្រាវជ្រាវមកឃើញថា៖

សាស្ត្រា ឬគម្ពីរក្នុងកម្ពុជរដ្ឋនេះ ដែលជាប្រភពនៃបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌ មាន ៣ បែប ដូចបានស្រង់យកមកសំដែងដោយសង្ខេប៖

### ១.១. សាស្ត្រាវិជ្ជាធរ

មានសេចក្តីថា " មានព្រះមហាថេរ ១រូប ឈ្មោះព្រះឧបគុត្តត្ថេរ លោកហោះជ្រែកក្រឡាមហាប្រឹថពីទៅកាន់ឋាននរកៗ ដោយអំណាចឫទ្ធិរបស់លោក មានផ្កាឈូកមាសប៉ុនកង់រាជរថផុសឡើងទទួលព្រះបាទលោក លោកក៏គង់ពែនលើផ្កាឈូកនោះអណ្តែតលើពពួកនរក ។ ហេតុតែអានុភាពព្រះថេរៈ ពួកសត្វពួកនរកបានដកដង្ហើមចេញចូលស្រួលមួយពេលនោះ ទើបនាំគ្នាសំពះព្រះថេរៈៗ មានព្រះទ័យករុណាសំដែងធម៌ ឲ្យ ស្តាប់, កាល ពួក សត្វ នរក បាន ស្តាប់ ធម៌ ហើយក៏ផ្តាំព័ត៌មានមកកាន់ញាតិសន្តាន របស់ខ្លួនទីទៃ ៗ ថា " ទូលព្រះបង្គំទាំងអស់គ្នាសព្វថ្ងៃនេះលំបាកវេទនាណាស់ ណាកម្តៅភ្លើងនរក ណាអត់អាហារ មិនដែលមានសាច់សាលោហិតណាលើកយក អាហារភោជន ឬ បច្ច័យបួនមក ឧបត្ថម្ភខ្ញុំម្តងណាទេ គឺខ្ញុំអត់ឃ្លាននោះខ្លាំងណាស់ រោគាព្យាធិជំងឺតម្កាត់ក៏មានច្រើនដែរបពិត្រព្រះមហាថេរបើព្រះករុណានិមន្តត្រឡប់ទៅកាន់មនុស្សលោកវិញ សូមព្រះអង្គមេត្តាផ្សព្វផ្សាយប្រាប់ម្តាយឪពុកបងប្អូនកូនចៅ ញាតិផៅសន្តានរបស់យើងខ្ញុំ មានឈ្មោះដូច្នេះៗនៅស្រុកឈ្មោះនេះៗ សូមឲ្យអាសូរករុណាមកដល់យើងខ្ញុំធ្វើបុណ្យនិមន្តព្រះសង្ឃមកដាក់បិណ្ឌឬកាន់បិណ្ឌផងរួចហើយផ្សព្វផ្សាយពរសព្វសាធុការផល្លានិសង្ស បុណ្យដាក់បិណ្ឌដល់ទូល ព្រះបង្គំទាំងអស់គ្នាផង ដើម្បីអោយបានផលជួយឧបត្ថម្ភឲ្យបានឆ្អែតស្កប់ស្កល់បាត់ទុក្ខវេទនា តទៅ"ៗ

កាលព្រះឧបគុត្តត្ថេរទទួលបណ្ដាំពពួកសត្វនរកហើយ ក៏ហោះត្រឡប់មកកាន់មនុស្សលោកវិញ បានចូលទៅថ្វាយព្រះពរព្រះមហាក្សត្រ ១ ព្រះអង្គ ព្រះមហាក្សត្រទ្រង់នាំនាហ្មឺនសព្វមុខមន្ត្រី សេដ្ឋីគហបតី និងអ្នកនគរជាច្រើននាក់ចូលទៅក្រាបបង្គំទូលព្រះដ៏មានបុណ្យថា "បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ! បើគ្រូបាធ្យាយ ម្ដាយឪពុក បងប្អូន កូនចៅ ញាតិមិត្តរបស់យើងខ្ញុំ អ្នកខ្លះមិនបានធ្វើបុណ្យឲ្យទានរក្សាសីលឡើយ ធ្វើតែអំពើបាប លុះអស់អាយុទៅ ៗ ទៅកើតក្នុងនរករងទុក្ខវេទនា អស់យើងខ្ញុំជាបងប្អូន កូនចៅ នៅឯក្រោយតើនឹងត្រូវធ្វើបុណ្យដូចម្ដេច ទើបឧទ្ទិសផលជូនទៅសត្វនរកទាំងនោះ ឲ្យលដោះចាកទុក្ខបាន ? " ។

ព្រះដ៏មានបុណ្យទ្រង់ត្រាស់តបថា " បើមហារាជចង់ធ្វើអំពើបុណ្យកុសលឧទ្ទិសផលជូនទៅសត្វនរកទាំងនោះ ឲ្យលដោះរួចមក ត្រូវធ្វើដូច្នេះ គឺចាប់ពីដើមថ្ងៃ **១ រោច** ខែ**ភទ្របទ**ទៅ ត្រូវធ្វើបាយបិណ្ឌ បាយបិតបូររាល់ថ្ងៃ ហើយត្រូវធ្វើអង្គព្រះពុទ្ធរូប ១ អង្គ ១ ថ្ងៃ ដរាបដល់ថ្ងៃ **១៥ រោច** ខែភទ្របទនោះឯង ត្រូវចងពិតាន ពាសរនាំងរាំងនន ក្រាលកម្រាល ត្រូវសមានទានចាំសីលឲ្យបរិសុទ្ធប្រាកដ ត្រូវបោសប្រាសគ្រវាសវត្តអារាមព្រះវិហារ ត្រូវរៀបរណ្ដាប់គ្រឿងបណ្ណាការ មានភ្ញីផ្កា គន្ធពិដោរជាដើម ហើយត្រូវនិមន្តព្រះគម្ដែងសង្ឃដ៏ទ្រង់សីលបរិសុទ្ធសូត្រធម៌មហាសម័យ ត្រូវប្រកាសបួងសួងអញ្ជើញគ្រូបាធ្យាយ ម្ដាយឪពុក បងប្អូន ញាតិកាលដែលចែកឋានទៅហើយទាំងប៉ុន្មាន មួយអន្លើដោយទេវតា ហើយត្រូវនិមន្តលោកទេសនាសាស្ត្រាវិជ្ជាធរជាតកក្នុងយប់នោះ លុះព្រឹកឡើងត្រូវធ្វើបាយបិណ្ឌ បាយបិត្តបូរ មានទាំងចង្ហាន់ផ្លែឈើនិងសារពើភោជនាអាហារផង ផ្គូផ្គាប់រណ្ដាប់អង្គាសដាក់បាត្រព្រះសង្ឃឧទ្ទិសផលជូនទៅដល់អស់ ពួកសត្វនរកទាំងនោះ ។

ដោយអានុភាពនៃអំពើកុសលផលបុណ្យនោះ សត្វនរកផងទាំងឡាយ នឹងបានរំដោះ ចេញអំពីទុក្ខភ័យឰដ៏កាលនោះ បានទៅកើតឰដ៏សួគ៌ទេវលោកនាយ ហើយសឹងឲ្យពរសព្ទសាធុការ មកញាតិសន្តានដែលបានធ្វើបុណ្យឲ្យទានឧទ្ទិសស្មោះចំពោះជូនទៅនោះឲ្យមានសុខសួស្ដីទីឃាយុយឺនយូរទីទៃៗឰដ៏កាលនោះហោង " ។

### ១.២. សាស្ត្រាអានិសង្សបិណ្ឌ

មានសេចក្តីថា " ព្រះដ៏មានបុណ្យទ្រង់ត្រាស់ចំពោះអនាថបិណ្ឌិកសេដ្ឋី ថា អស់ម្តាយឪពុកញាតិការវង្សាបងប្អូនកូនចៅរបស់ជនទាំងឡាយ ដែលស្លាប់ទៅអំពីមុនៗនោះ ទោះទៅកើតឯណាៗក្តី តែដល់រនោចខែភទ្របទដែលគេរៀបកាន់បិណ្ឌ តែងតែមកជួបជុំនៅពេលនោះ ។ ហេតុតែតេជៈអានិសង្សនៃបុណ្យដែលអស់ញាតិសន្តានបានធ្វើបាយបិណ្ឌ បាយបិត្តបូរនាខែភទ្របទ ហើយឧទ្ទិសផលជូនទៅនោះ ក៏បានរំដោះរួចចេញអំពីនរកប្រេតនោះហោង " ។

រីឯសត្វនរកប្រេតផងទាំងឡាយ ដែលមកកាន់ឋានមនុស្សលោកក្នុងខែភទ្របទនោះ ប្រេតខ្លះមកកើតជាកណ្តូបខ្មោចទំយំនៅជំបូលផ្ទះ ខ្លះមកទំយំនៅចុងកាត់ផ្ទះ ថ្នឹមផ្ទះ មាត់ទ្វារផ្ទះ ជើងជណ្តើរផ្ទះ ដើមឈើក្បែរផ្ទះ ប្រេតខ្លះមកដល់ពាក់កណ្តាលផ្លូវ ខ្លះមកចំអើតមើលទៅមក ខ្លះបាំងដៃមើលមកអំពីចម្ងាយ ហើយគិតអាណិតអនិច្ចាខ្លួនថា " ឱរូបអញអើយ ! អភ័ព្វអ្វីម្ល៉េះមកកើតជាប្រេតនរករងទុក្ខវេទនាទូរាទូរន់ពន់ ប្រមាណ យូរឆ្នាំហើយ កើតសម្រេកគម្លានក្រៃពេក " ។

សត្វនរកប្រេតទាំងនោះ កាលបើដល់ខែភទ្របទ ដែលជនទាំងឡាយបានរៀបរណ្តាប់បាយបិណ្ឌបាយបិត្តបូរ ឧទ្ទិសផលានិសង្សបញ្ជូនទៅ ក៏សឹងតែបានលដោះរួចមកហោង ។

ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា៖ ហែអនាថបណ្ឌិត ! នៅថ្ងៃភ្ជុំបិណ្ឌនោះត្រូវចងរំយោលចងទង់-ពិតាន ដាសពាសន្ទូវនាំងរាំងននជាដើម ហើយរៀបរណ្តាប់គ្រឿងបណ្ណាការ គឺទៀនធូបភ្ញីផ្កាស្លាម្លូនឹងគ្រឿងគន្ធពិដោរ ព្រមទាំងផ្លែឈើតូចធំនំចំណីភោជនាអាហារផង បូជាព្រះសង្ឃ ។

ផលានិសង្សនៃបុណ្យនោះ ក៏ជូនទៅដល់ជីដូនជីតាម្តាយឪពុកបងប្អូនកូនចៅញាតិផៅទាំង៧ សន្តាន ដែលស្លាប់ទៅ ។ កើតជាប្រេតនរករងទុក្ខវេទនានោះ ឲ្យបានសម្បត្តិសួគ៌សម្បត្តិនិព្វានជាឋានបរមសុខប្រសើរហោង។

ហែអនាថបណ្ឌិត! នរូបុរសបុគ្គលប្រុស ស្រីឯណានីមួយបើនឹងរៀបកាន់បិណ្ឌនោះត្រូវអញ្ជើញអស់មេបាចាស់ទុំផងទាំងឡាយមកអង្គុយជុំវិញ ហើយទុកលង្វែក

ចន្លោះកណ្តាលប្រមាណ ១ ហត្ថ យកត្រីសាច់អាហារភោជននឹងផ្លែឈើតូចធំអន្សមនំគមនួវចេកអំពៅត្រាវដំឡូងដូងត្នោតព្រមទាំងគ្រឿងបណ្ណាការ ផង គឺយកទៀនធូបភ្ញីផ្កា ស្លាម្លូប្រេងម្សៅមកបូជាព្រះរតនត្រ័យ ហើយឲ្យមេបាចាស់ទុំស្មាលាទោសឲ្យ ដ្បិតប្រេតនោះ ផ្តាំមកថា ឲ្យអស់ញាតិកាមេបាចាស់ទុំជីដូនជីតា ម្តាយឪពុក បងប្អូនកូនចៅ ស្មាលាទោសឲ្យផង កុំឲ្យមានវេរាកម្មតាមទៅឡើយ។

បើក្នុងខែភទ្របទនោះ មិនមានអ្នកណារៀបរណ្តាប់បាយបិណ្ឌ បាយបិត្តបូរបូជាព្រះរតនត្រ័យបញ្ជូនផលទៅទេ អស់ប្រេតនរកអំបាលនោះ ក៏អត់បាយអត់ទឹកស្រេកឃ្លានរងទុក្ខវេទនាក្រៃពេក ម៉្លោះហើយប្រេតទាំងនោះ ក៏ជេរប្រទេចផ្តាសាមកញាតិកាទាំងឡាយឲ្យហិនហោចទ្រព្យសម្បត្តិ ព្រាត់ម្តាយឪពុកប្តីប្រពន្ធកូនចៅញាតិផៅទាំង ៧ សន្តានជាដើម ។ល។

### ១.៣. គម្ពីរបេតវត្ថុ

មានសេចក្តីថា " មានព្រានម្នាក់នៅក្នុងក្រុងពារាណសីតែងទៅបាញ់សត្វក្នុងព្រៃ ចិញ្ចឹមជីវិតរាល់ថ្ងៃ វេលាត្រឡប់មកផ្ទះវិញ ពួកក្មេងៗ តែងចោមរោមសុំសាច់រាល់ដង ។ ថ្ងៃ ១ ព្រាននោះទៅបាញ់មិនបានសត្វក៏បេះផ្កាត្របែកព្រៃ (អាចារ្យខ្លះថាផ្ការាជព្រឹក្ស) ប្រដាប់ខ្លួន នឹងរែកយកមកផ្ទះជាច្រើន លុះដល់ទ្វារភូមិពួកក្មេងៗ មកសុំសាច់ដូចសព្វដងទៀត ព្រានក៏ចែកផ្កាត្របែកព្រៃឲ្យម្នាក់ ១ ស្មើង ។ លុះព្រាននោះស្លាប់ទៅ ៗ កើតជាប្រេតអាក្រាត មានផ្កាត្របែកព្រៃប្រដាប់ក្បាលដើរទៅក្នុងទឹក សំដៅទៅផ្ទះញាតិរបស់ខ្លួនដើម្បីរកអាហារបរិភោគ ។ វេលានោះ កោសិយអាមាត្យ ជាអាមាត្យព្រះបាទពិម្ពិសារជិះទូកទៅបង្រ្កាបស្រុកបច្ចន្តគ្រាមបាន ឃើញប្រេតនោះ សួរដឹងសេចក្តីហើយក៏មានសេចក្តីអាណិត ទើបនិយាយថា " សត្វរបស់យើងមានធ្វើម្តេចអ្នកនឹងទទួលបរិភោគបាន ? " ។ ប្រេតឆ្លើយថា " ក្នុងទូកនេះបើមានឧបាសកអ្នកដំកល់ខ្លួននៅក្នុងត្រៃសរណគមន៍ សូមលោកឲ្យសត្វរដល់ឧបាសកនោះ ហើយឧទ្ទិសចំណែកកុសលឲ្យខ្ញុំចុះ " ។ កោសិយអាមាត្យធ្វើតាម ប្រេតបានទទួលអនុមោទនាហើយ បានសេចក្តីសុខ ទើបផ្តាំថា " សូមឲ្យលោកមេត្តាដល់ប្រេតឯទៀតៗ ផង កាលលោកធ្វើកុសលឯណានីមួយហើយ សូមឲ្យ

ឧទ្ទិសចំណែកកុសលឲ្យប្រេតខ្លះផង ” ។ កាលអាមាត្យនោះត្រឡប់មកដល់ស្រុកវិញ បានថ្វាយទានចំពោះព្រះពុទ្ធ នឹងព្រះភិក្ខុសង្ឃ ហើយក្រាបទូលរឿងប្រេតនោះថ្វាយទ្រង់ជ្រាប ។ ព្រះបរមសាស្ដាទ្រង់អធិដ្ឋានឲ្យពុទ្ធបរិស័ទមកប្រជុំគ្នា ហើយទ្រង់សំដែងបេតនិកាយ ( រឿងពួកប្រេត ) ឲ្យប្រាកដឡើង ដូចដែលបានពោលមកខាងលើនេះ ។

## ១.៤. តាមប្រវត្តិសាស្ត្រជាតិ

បើតាមតម្រាចារតាម ប្រវត្តិសាស្ត្រនៃ ប្រទេស កម្ពុជាយើង បានបង្ហាញថាពិធីបុណ្យភ្ជុំបិណ្ឌគឺកើតមានតាំងពីបុរាណកាលមក ម្ល៉េះ។ ប៉ុន្តែទាស់ត្រង់ថា កាលពីសម័យមុនគេមិនហៅថា បុណ្យភ្ជុំទេ ដោយនៅក្នុងពិធីនេះគេមានបែងចែកចេញជាពីរថ្នាក់។ ថ្នាក់ដំបូង គឺ គេចាប់ផ្ដើមធ្វើចាប់ពីថ្ងៃ ១រោច រហូតដល់ថ្ងៃ ១៤រោច ជាវារកកត្ត (កត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់។ ចំណែកមួយថ្នាក់ទៀតគេធ្វើនៅថ្ងៃ ១៥រោច ដែលគេហៅថាបុណ្យភ្ជុំ។ ពិធីបុណ្យទាំងពីរថ្នាក់នេះ បច្ចុប្បន្នត្រូវបានយើងបូកបញ្ចូលគ្នា ហើយហៅកាត់ថា ពិធីបុណ្យបិណ្ឌភ្ជុំនេះឯង។

ពិធីបុណ្យភ្ជុំបិណ្ឌមាន ដើមកំណើតនៅសម័យអង្គរនៅពេលដែលប្រជាជនធ្វើតាមសត្វមុនព្រះព្រហ្ម ឬព្រះពុទ្ធសាសនា។ ប្រសិន បើយោងទៅ តាមព្រះគម្ពីរដែលទាក់ទងទៅនឹង ពិធីបុណ្យភ្ជុំបិណ្ឌ គឺ មានភាពស្មុគស្មាញច្រើន ប៉ុន្តែព្រះគម្ពីរដំបូងពាក់ព័ន្ធមានព្រះសង្ឃ៥អង្គបានចរចាជាមួយព្រលឹងខ្មោច។ ក្នុងព្រះគម្ពីរទី២ មន្ត្រីរាជការ និង ទាហាន ជាច្រើន បានទទួលបញ្ជា របស់ស្ដេច ឲ្យទៅ ធ្វើសង្គ្រាម។ នៅ លើ សំពៅនៅ ពេលយប់ ពួកគេបាន ជួបជាមួយ នឹង ព្រលឹង ខ្មោច អត់ឃ្លាន។ មន្ត្រីរាជការ និង ទាហាន បានសួរ ថា "តើពួក យើងអាច ឲ្យចំណីអាហារទៅឲ្យអ្នកដោយរបៀបណា? " ព្រលឹងខ្មោច បានឆ្លើយ "អ្នកអាច ឲ្យ ចំណីអាហារទៅមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងអស់ដែល ប្រតិបត្តិ សីលឬសីល៨ហើយហៅឈ្មោះរបស់ពួកយើង"។បើយោងទៅតាមព្រះតេជគុណ អ៊ុំ សាម បានឲ្យដឹងថា ជាយូរណាស់មក ហើយ ព្រះសង្ឃ ពុទ្ធសាសនាបាន ដើរគ្រប់ ទីកន្លែង ដើម្បី បិណ្ឌបាត្រមិនថាជួបនឹងអាកាសធាតុអាក្រក់យ៉ាងណានោះទេ។

ក្រោយមកក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នដែលជាអ្នកតស៊ូដ៏ខ្លាំងនៃព្រះពុទ្ធសាសនា បានគាំទ្រ នឹងផ្ដល់ ឲ្យ ព្រះសង្ឃ ពុទ្ធសាសនានូវរបស់ចាំបាច់ ចំនួន ៤ គឺ សំលៀក-បំពាក់ អាហារ ជំរក និង ថ្នាំពេទ្យ។ ស្ដេច ដឹង ថា នៅពេល ដែល ព្រះសង្ឃ ដើរ បិណ្ឌបាត្រ ក្នុង រដូវ វស្សានេះជួប ប្រទះនឹងភ្លៀងផ្គរ យ៉ាងខ្លាំង។ ស្ដេចមានចិត្ត អាណិតអាសូរ ដល់ ព្រះសង្ឃ យ៉ាងខ្លាំង ដូច្នេះបាន ស្នើរ សុំមិន ឲ្យ ព្រះសង្ឃដើរ បិណ្ឌបាត្ររយៈពេល៣ ខែរៀងរាល់រដូវវស្សា។ ដូច្នេះស្ដេចក៏បាន អំពាវនាវដល់ ប្រជាជនទាំងអស់ ឲ្យ ផ្ដល់ជូននូវអាហារ និង តំរូវការមូលដ្ឋានផ្សេងទៀត សម្រាប់ ព្រះសង្ឃក្នុងរយៈពេលនេះ។អ្នកដើរតាមព្រះពុទ្ធនឹងទទួលបានកុសលផលបុណ្យ ជាច្រើន។ជាលទ្ធផលមានមនុស្សកាន់តែច្រើនបានផ្ដល់ជូននូវតំរូវការចាំបាច់ទាំង៤ ដល់ព្រះសង្ឃ។ និទ្ទាការនេះ បានបង្កើត ឲ្យមានគម្ពីរមួយទៀត ស្ដី អំពី ពិធី បុណ្យ ភ្ជុំបិណ្ឌ។

## ២. មូលហេតុដែលប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ

ប្រជាជនខ្មែរ ក៏ តែង តែ ចងចាំ និង យល់ គ្រប់ៗគ្នាថា "បុណ្យភ្ជុំបិណ្ឌ" គឺជាការធ្វើបុណ្យដាក់បិណ្ឌ ដើម្បីឧទ្ទិសដល់ ប្រេតបុគ្គលជាឪពុក ម្ដាយ បងប្អូន ញាតិសន្ដានទាំងឡាយដែលបានចែកស្ថានទៅហើយមិនដឹងជាទៅចាប់កំណើត នៅលោកខាងមុខជាអ្វីនោះ។ ប៉ុន្ដែ បើតាម អត្ថបទរបស់ លោក សុង ស៊ីវ វិញ ការធ្វើបុណ្យភ្ជុំបិណ្ឌ ពុំមែនមានន័យ តែប៉ុណ្ណឹងទេ គឺ លោកបានបកស្រាយដោយ លើកយកអត្ថន័យចំនួន ៣ គឺ :

ក. ដើម្បីឧទ្ទិសកុសលចំពោះបេតបុគ្គល ឬប្រេតបុគ្គល (ពាក្យ "បេត" ជាពាក្យបាលី ឯ ពាក្យ "ប្រេត" ជាពាក្យសំស្ក្រឹត)

ខ. ដើម្បីឲ្យបានសេចក្ដីសុខចម្រើន សិរីសួស្ដីដែលកើតពីផលទានរបស់ខ្លួន។

គ. ដើម្បីបង្កើតសាមគ្គីរបស់ជាតិ គឺ ការស្រុះ ស្រួល គ្នាទាំងពេលវេលាកំណត់ ទាំងការ ធ្វើនំគមអន្សមពេញទូទាំង ព្រះរាជាណាចក្រកម្ពុជា យើងក៏អាចកត់សម្គាល់ នូវពាក្យមួយទៀតថា"បុណ្យសែនដូនតា"ដែលជាពាក្យសាមញ្ញសម្រាប់ប្រជារាស្ត្រ ខ្លះព្រោះថាពាក្យទាំងពីរគឺមានន័យដូចគ្នា។កាលពីសម័យ បុរាណកាល គេធ្វើពិធី

បុណ្យនេះគឺដើម្បីរៀបចំធ្វើសង្ឃភត្ត ទំនុកបម្រុងព្រះសង្ឃដែលគង់ចាំវស្សាក្នុងវត្ត រយៈពេល៣ខែ ចាប់តាំងពីថ្ងៃចូលវស្សារហូតដល់ថ្ងៃចេញវស្សា។ នៅក្នុងចំណោរកាលបុរាណបានចារថា ដោយនៅក្នុងរដូវវស្សាមានភ្លៀងធ្លាក់ជោកជាំ រលឹមពព្រិច ធ្វើឲ្យមានការលំបាកដល់ព្រះសង្ឃក្នុងពេលធ្វើគោចរបិណ្ឌបាត។ ហេតុដូច្នេះ ទើបបណ្ដាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃរហូតដល់ថ្ងៃចេញវស្សា។ ម្យ៉ាងវិញទៀត នៅក្នុងពិធីបុណ្យនេះ គឺធ្វើឡើងដើម្បីផ្សាយឧទ្ទិសកុសលដល់ពពួកបេតជនញាតិ និងញាតិទាំង៧សណ្ដាន ព្រមទាំងតំណញាតិច្រើន មហាកប្បនោះ ផងដែរ តាមរយៈ អនុភាព នៃ សង្ឃគតាទក្ខិណាទាន ដែលរស់រងទុក្ខវេទនា កើតជាប្រេតមានកម្មពៀរ ជាប់ទោសធ្ងន់ រង កម្មក្រហល់ ក្រហាយ អត់ ឃ្លាន ទាំងអស់ នោះ បានរួចផុតពីក្ដីលំបាកសោកសៅ។ ម្យ៉ាងទៀតប្រជាជនខ្មែរប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ ដោយ សារ តែពួកគេបានជំនឿយ៉ាង មុត មាំតាមបណ្ដាំចាស់ៗ ដែលពោល ណែនាំ និងអនុវត្តជា រៀងរាល់ឆ្នាំតៗគ្នាមក។ គេជឿ ថា សាច់ ញាត្តិ ដែល បាន ចែក ឋាន ទៅ ហើយ មាន មាតា បិតាជីដូន ជីតា បង ប្អូន កូន ចៅ ញាតិកា ទាំង៧ សន្ដាន នោះ ដែលខ្វះមាន បាបកម្មត្រូវទទួល ទោស នៅ ឋាន នរក កើត ជា ប្រេត កើត ជា អបាយ ភូមិវេទនាណាស់។ ឋាននោះ ស្ថិត នៅ ជ្រៅ ឆ្ងាយ ពី ឋាន មនុស្ស មិនអាចមើល ឃើញពន្លឺព្រះអាទិត្យ ទេ គ្មានសំលៀកបំពាក់ គ្មាន អាហារ បរិភោគ ឡើយ។ លុះ ដល់ រដូវបុណ្យគេ ដោះលែង ឲ្យ មក ទទួល ផល្លានិសង្ឃ ដែលសាច់សាលោហិតធ្វើបុណ្យឧទ្ទិសឲ្យ។ ប្រជាជន ខ្មែរ ជឿ ថា ព្រលឹង របស់អ្នកទាំងនោះ នឹងមកដល់វត្តអារាមហើយ ទទួលការផ្ដល់ជូនពីសាច់ញាត្តិឬកូនចៅរបស់ពួកគេតាមរយះ ការអធិដ្ឋានដោយព្រះសង្ឃ។ ម្យ៉ាងទៀតគេខ្លាចជីដូនជីតាដាក់ ប្រទេចបណ្ដាសាឲ្យ គេ ហិនហោចប្រសិនបើដើរស្វែងរកគ្រប់៧វត្តហើយនៅមិនឃើញ សាច់ ញាត្តិ ធ្វើ បុណ្យឧទ្ទិសឲ្យ។មួយវិញទៀតគេសង្ឃឹមថាកុសល ផលបុណ្យដែលគេបានធ្វើនៅជាតិនេះ នឹងធ្វើឲ្យគេទទួលបាននូវសេចក្ដីសុខ សេចក្ដីចំរើនរហូតដល់ជាតិក្រោយ។ ទំនាក់ទំនងបុណ្យភ្ជុំបិណ្ឌ និង បុណ្យ ចូល វស្សា បើ តាម សង្ឃដីការបស់ សម្ដេច

ព្រះមង្គលទេពាចារ្យ អ៊ុំ ស៊ុម បានឲ្យដឹងថា នៅសម័យដើមគឺ ក្រោយពេលដែល ព្រះពុទ្ធសាសនា បាន ផ្សាយចូលមកក្នុងប្រទេសខ្មែរយើង ហើយនោះ ភិក្ខុសង្ឃបាននិមន្ត ទៅបិណ្ឌបាតគ្រប់ច្រកល្ហករាល់ពេលវេលា ដោយមិនគិតថាជារដូវវស្សា រដូវប្រាំង រដូវក្ដៅ ឬរដូវរងាឡើយ ។

លុះដល់សម័យស្ដេចសោយរាជ្យ គឺ វង្ស "ជ័យវរ្ម័ន" ព្រះអង្គមានព្រះទ័យជ្រះថ្លានឹងព្រះពុទ្ធសាសនាក៏បានឧបត្ថម្ភព្រះសង្ឃដែលបួសក្នុង ព្រះពុទ្ធសាសនា ដោយបច្ច័យបួន មានចង្ហាន់បិណ្ឌបាត្រ សេនាសណៈ ភេសជ្ជៈ និង ចីវរ ។ ក្រោយមកទៀត ព្រះអង្គទ្រង់ឈ្វេងយល់ថានៅរដូវវស្សាព្រះសង្ឃនិមន្តចេញទៅបិណ្ឌ បាត្រនោះជួបប្រទះនូវការលំបាក ខ្លាំងណាស់ដូចជា ភ្លៀង ផ្គរ រន្ទះ ខ្យល់បក់បោកដែល បណ្ដាលឲ្យព្រះសង្ឃអង្គខ្លះ ត្រូវដួលលើកក់ជ្រាំនោះ ក៏នាំឲ្យព្រះអង្គកើតព្រះទ័យសង្វេគ ផង ជ្រះថ្លា ផង ហើយ ក៏ បាន បវរណា ដល់ ព្រះសង្ឃ ក្នុង ព្រះរាជាណាចក្រកម្ពុជា ឲ្យនិមន្តគង់នៅក្នុងវត្ត ហើយកុំនិមន្តចេញ បិណ្ឌបាត្រឯណា ក្នុងរយៈពេល ៣ខែ មិនតែប៉ុណ្ណោះព្រះអង្គក៏បានធ្វើជា ព្រះរាជប្រកាសផ្សព្វផ្សាយ ឲ្យប្រជារាស្ត្រទាំងអស់ក្នុង ព្រះរាជាណាចក្រកម្ពុជាជួយឧបត្ថម្ភបច្ច័យបួនដល់ ព្រះសង្ឃក្នុង រយៈពេលនៃ រដូវវស្សាកុំឲ្យ ព្រះសង្ឃនិមន្តបិណ្ឌបាត្រនៅខាងក្រៅទៀត។

ការអនុវត្តន៍បែបនេះចេះ តែក្លាយបន្តិចម្ដងៗ ប្រជារាស្ត្រក៏ធ្វើតាម ព្រះរាជារហូតមក គឺ ឲ្យ តែ ដល់ រដូវ វស្សា រយៈពេល **៣ខែ** ដោយ គិត ចាប់ ពី ថ្ងៃ **១ រោច ខែអាសាឍ**ដល់**ថ្ងៃពេញបូរមីខែអស្សុជ**មិនឲ្យព្រះសង្ឃទៅណាទេ (គឺនៅសម័យនោះ គេដាក់បិណ្ឌក្នុង រយៈពេល **៣ខែ** តែក្រោយៗមកក៏សល់រយៈពេលតិចទៅៗរហូតមកដល់សព្វថ្ងៃនេះ អាស្រ័យដោយកត្តាជីវភាពរស់នៅក្នុងសង្គមមានការប្រែប្រួល)។

## ៣. ការប្រារព្វពិធីបុណ្យភ្ជុំបិណ្ឌ

### ៣.១. បុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ

កាលពិចារណាតាមរឿងក្នុងសាស្ត្រា និងគម្ពីរដែលពោលមកនោះ ឃើញថា៖ របៀបបុណ្យកាន់បិណ្ឌនឹងភ្ជុំបិណ្ឌក្នុងកម្ពុជរដ្ឋយើងនេះ ត្រូវតាមសេចក្ដីក្នុង

សាស្ត្រាវិជ្ជាធរខ្លះ សាស្ត្រាអានិសង្សបិណ្ឌខ្លះ គម្ពីរបេតវត្ថុខ្លះ គឺត្រង់របៀបរៀបចំការបុណ្យហើយនឹងកំណត់ថ្ងៃ ខែ នឹងពេលដែលធ្វើ ត្រូវតាមសាស្ត្រាវិជ្ជាធរ នឹងសាស្ត្រាអានិសង្សបិណ្ឌទាំងអស់ របៀបធ្វើផ្កាបិណ្ឌ និងកិច្ចឧទ្ទិសផលបញ្ជូនទៅប្រេតតាមគម្ពីរបេតវត្ថុដោយច្រើន គឺផ្កាបិណ្ឌដែលគេធ្វើឧទ្ទិសឲ្យប្រេត គេធ្វើប្រដាប់ដោយផ្កាឈើស្លាន់ក្រាប់ ឬក្រដាសពណ៌នោះប្រហែលនឹងអាការរបស់ប្រេតដែលគម្ពីរបេតវត្ថុ ចែងថា " ប្រេតមានផ្កាត្របែកព្រៃ ប្រដាប់ក្បាល ដើរមករកអាហារឯផ្ទះញាតិរបស់ខ្លួននោះឯង " ។

ការដែលពុទ្ធិកជនជាតិខ្មែរ នាំគ្នាធ្វើបុណ្យកាន់បិណ្ឌពល់ឆ្នាំ មិនហ៊ានខាន គឺតែដល់ថ្ងៃ ១ រោច ខែភទ្របទ តែងនាំគ្នាទៅកាន់បិណ្ឌក្នុងទីអារាមពល់ថ្ងៃ ដរាបដល់ថ្ងៃ ១៥ រោច ហៅថា " ភ្ជុំបិណ្ឌ " នោះ ទោះបីអ្នកក្រីក្រលំបាក ឬអ្នកផឹកប្រមឹកយ៉ាងណា ក៏ធ្វើឲ្យបានយ៉ាងតិចណាស់ ត្រឹមថ្ងៃភ្ជុំជាថ្ងៃបង្ហើយពុំហ៊ានខាន, ទាំងនេះក៏ដោយហេតុគេជឿតាមសាស្ត្រាវិជ្ជាធរនឹងសាស្ត្រាអានិសង្ស បិណ្ឌ ហើយនឹងជឿតាមសណ្តាប់ចាស់ៗ ដែលធ្លាប់ធ្វើឲ្យឃើញរៀងមក ប្រកាន់មាំក្នុងចិត្ត គិតអាណិតផង ខ្លាចផង, ឯអាណិតនោះ គឺអាណិតដល់ជីដូនជីតា ដែលនាំគ្នាមកទទួលយកផល ឯខ្លាចនោះ គឺខ្លាចប្រេតដែលមក បើមិនឃើញម្តាយឪពុកបងប្អូនកូនចៅញាតិផៅទៅធ្វើបុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌទេនឹងដេរប្រទេចផ្តាសាឲ្យហិនហោចខ្ទេចផ្សាវិនាសទ្រព្យ សម្បត្តិ ។

ឯសាស្ត្រាវិជ្ជាធរ នឹងសាស្ត្រាអានិសង្សបិណ្ឌ ក្នុងកម្ពុជរដ្ឋយោងនេះ មានតែសម្រាយភាសាខ្មែរ គ្មានភាសាបាលី ហើយគ្មានឈ្មោះអ្នកតែង មិនដឹងជាតែងក្នុងសម័យណា ។ ចំណែកឯគម្ពីរបេតវត្ថុមានទាំងភាសាបាលី ភាសាខ្មែរ ហើយគម្ពីរនេះ ជាអដ្ឋកថាព្រះត្រៃបិដកខុទ្ទកនិកាយ ព្រះអាចារ្យធម្មបាលតែងក្នុងសតវត្សជាមួយនឹងអដ្ឋកថាទាំងពួង ។

ឯសាស្ត្រា ឬគម្ពីរដែលចែងអំពីការធ្វើបុណ្យឧទ្ទិសផលឲ្យដល់បេតជនដែលលះលោកនេះទៅកាន់បរលោកនោះ ទោះជាសាស្ត្រាសម្រាយក្តី មិនជាប្រមាណទេ គឺយក តែត្រង់ ពុទ្ធានុញ្ញាតឲ្យធ្វើទក្ខិណានុប្បទានឧទ្ទិសផលទៅឲ្យ សត្វគ្រប់ជំពូក

ដើម្បីឲ្យរួចលដោះចាកអបាយទុក្ខទាំងពួង នោះឯង ជាប្រមាណ ។

បុណ្យបិណ្ឌភ្ជុំនេះបុរាណាចារ្យរាជបណ្ឌិតខ្មែរយើងបានរៀបចំរយៈពេល១៥ថ្ងៃ ដោយចាប់គិតពីថ្ងៃទី០១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ ជាពិធីមួយសម្រាប់ឧទ្ទិសកុសលទៅដល់បេតជនញាតិដែលបានស្លាប់ទៅ។នៅក្នុង រយៈពេល ១៤ថ្ងៃនៃការកាន់បិណ្ឌ ឬដាក់បិណ្ឌនេះ ពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ជាពិសេសក្រុមនីមួយៗដែលបានរៀបចំជា ក្រុមដោយលោកតាអាចារ្យចាត់ចែងនោះ ត្រូវបែងចែកចេញ៣ឬ៤ក្រុមតូចៗ ដើម្បីរៀបចំធ្វើយាគូ ឬធ្វើភត្តាហារជា៣ទៅ៤ឆ្នាំងស្មើនឹង៣ទៅ៤មុខម្ហូប។ ពេលទូងស្គរចំណាំវស្សា អ្នកនៅក្នុងក្រុមវេននីមួយៗត្រូវចាប់ផ្តើមធ្វើចង្ហាន់ ហើយយាយតាចាស់ៗក្នុងក្រុមវេន ត្រូវជ្រើសរើសយកផ្ទះណាមួយដើម្បីប្រមូលនំនែករៀបចំបាយបិណ្ឌ បាយបត្តបូរ។ រៀបចំរួចហើយត្រូវនាំគ្នាទៅវត្តស្តាប់លោកសូត្រថ្វាយបង្គំធម៌ សុខោ និងធម៌បរាភវសូត្រ។ ចំណែកឯកូនចៅដែលនៅផ្ទះ ត្រូវនាំគ្នាខិតខំដុតដៃដុតជើងបបរឬស្ងស្ទុកតាមមុខម្ហូបនីមួយៗ ដោយឡែកពីគ្នា។ លុះដល់ពេលព្រឹកព្រាងអរុណោទ័យត្រូវនាំគ្នារៀបចំខ្លួនកណ្តៀត យួរ កាន់ ទូល វែកចង្ហាន់ទៅវត្ត។

នៅក្នុងវត្ត លោកតាអាចារ្យត្រូវរៀបចំពីធីរាប់បាត្រនៅលើឧបដ្ឋានសាលា។ បន្ទាប់មកលោកអាចារ្យជាប្រធាន ត្រូវនាំពុទ្ធបរិស័ទវេរចង្ហាន់ប្រគេនព្រះសង្ឃ វេរបាយបត្តបូរ។ល។ លុះដល់ពេលព្រះសង្ឃធ្វើបត្តានុមោទនគាថាចប់ មេវេនក្រុមនីមួយៗត្រូវរៀបចំម្ហូបអាហារ ចំណីចូលគំនាប់ជូនលោកតាអាចារ្យវត្ត ព្រមទាំងចាត់ចែងភោជនាហារទទួលភ្ញៀវដែលអញ្ជើញទៅបុណ្យនៅក្នុងថ្ងៃ វេនរបស់ខ្លួននោះផងដែរ។ការប្រគេនចង្ហានដល់ព្រះសង្ឃ ត្រូវបានធ្វើឡើងដើម្បីឧទិសកោសលឲទៅជីដូនជីតាងបងប្អូននិងញាតិទាំង៧សណ្តាន ដែលបានស្លាប់ក្លាយជាប្រេតហើយត្រូវបានជាប់ឃុំនៅក្នុងនរក។ ក្នុងការបើទ្វា នរកនេះប្រេតខ្វះ មានឳកាសរួចផុតពីការជាប់ទារុណកម្មនៅនរកខណៈ ដែលខ្វះទៀតត្រូវបានគេ ដោះលែងឲនៅក្រៅនរកជាបណ្តោះអាសន្នដើម្បីទៅទទួលយកនូវចំណី និងកោសលផលបុណ្យ ដែល

កូនចៅបានឧទិសឲ្យហើយនឹងត្រូវត្រឡប់ទៅទទួលទុក្ខវេទនានៅក្នុងនរកបន្តទៀត បន្ទាប់ពីពិធីភ្ជុំបិណ្ឌនេះត្រូវបានបញ្ចប់។ ចំពោះញាតិសណ្ដាន ដែល មិនបាននៅក្នុងនរកក៏ដោយក្ដី ក៏ត្រូវបាន គេចាត់ទុក ថាអាចទទួលបាននូវ កោសលពីពិធីការឧទិសក្នុងពិធី បុណ្យនេះផងដែរ។ ដោយហេតុ ពុទ្ធសាសនិកមានការមមាញឹកចំពោះកិច្ចានុកិច្ចប្រចាំថ្ងៃនិងដើម្បីធានាថាព្រះសង្ឃត្រូវបានផ្គត់ផ្គង់ជាទៀងទាត់នោះទើបគេ ចែកជាក្រុមៗដាក់វេណគ្នា យកទេយ្យទាន ទៅប្រគេនព្រះសង្ឃរយៈ-ពេល១៤ថ្ងៃចាប់ពីថ្ងៃ១រោចដល់ថ្ងៃ១៤រោចខែកទ្រុបទហើយអោយឈ្មោះថាវេណទី១.វេណទី១៤។

រយៈពេល១៤ថ្ងៃនេះអោយឈ្មោះថាបុណ្យកាន់បិណ្ឌឬបុណ្យដាក់បិណ្ឌ ចំណែកថ្ងៃ១៥រោចដែលជាថ្ងៃចុង ក្រោយនោះ ពុទ្ធសាសនិកពី គ្រប់វេណទាំងអស់បានមកជួបជុំគ្នាធ្វើទានចំពោះសង្ឃជាមួយគ្នាដើម្បី បញ្ចប់បុណ្យកាន់បិណ្ឌ ថ្ងៃទី ១៥ ត្រូវនឹងថ្ងៃ១៥រោច ខែកទ្រុបទ ដែលជា ថ្ងៃចុងក្រោយនេះអោយឈ្មោះថាភ្ជុំបិណ្ឌ ឬថ្ងៃភ្ជុំបិណ្ឌ។ សូមបញ្ជាក់ដែរ ថា ក្នុងថ្ងៃបុណ្យភ្ជុំ មានរៀបចំកញ្ចប់ចតុប្បច្ច័យ (ស៊ង) ប្រគេនគ្រប់ភិក្ខុសាមណេរ។ ឯគណៈកម្មការវត្តបានចាត់ចែងនំអន្សម នំគម និងបាយបត្តបូរឲ្យទៅសិស្សគណទុកប្រគេនភិក្ខុសាមណេរតាមចំណែក សម្រាប់ធ្វើចង្ហាន់នៅព្រឹកថ្ងៃបន្ទាប់។ ម្យ៉ាងវិញទៀត ថ្ងៃបុណ្យភ្ជុំបិណ្ឌនេះ កាលពីសម័យបុរាណមានលេងល្បែងប្រណាំងក្របី សេះ ចាប់ពី២-៣គូ ទៅតាមតំបន់រៀងៗខ្លួនដើម្បីអបអរនៅក្នុងថ្ងៃបុណ្យធ្លងបង្ហើយ។ លើសពីនេះទៅទៀតក្របី សេះ និងរបស់ដែលត្រូវប្រកួត គេបានតុបតែងលំអដោយប្រេង លាបពណ៌រលើបរលោង មានពាក់ប្រឡៅ កណ្ដឹងត្រដោក ឬចង្រ្កងជាដើម។ កន្លែងខ្លះទៀតមានលេងល្បែងផ្សេងៗខុសពីនេះ។ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ ទំនៀមទម្លាប់នេះចេះតែបាត់ៗ រួញថយបន្តិចម្ដងៗ សាសនាកាន់តែកន្លងវែងទៅ នាំឲ្យការប្រកាន់ខ្ជាប់ស្មើរតែបាត់បង់ច្រើនណាស់ដែរ។

### ៣.២. បរាភវសូត្រ

បរាភវសូត្រ (អានថា ប៉ៈ រ៉ា ភៈ វៈ) តែងត្រូវបានព្រះសង្ឃសូត្រនៅក្នុងព្រះវិហារជារៀងរាល់ ថ្ងៃ នា ពេល ទៀបភ្លឺ នៅ ក្នុង អំឡុង ពេល បុណ្យ កាន់ បិណ្ឌ។ នៅ ក្នុង បរាភវសូត្រនេះ ជារឿយៗគេឮឃ្លាមួយដែលថា នាំឲ្យវិនាស។ ឃ្លានេះជាហេតុនាំឲ្យអ្នកខ្លះមានទស្សនៈថា ពួកគេមិនហ៊ានស្តាប់ធម៌បរាភវសូត្រទេ ព្រោះខ្លាចវិនាស។

តាមពិតបរាភវសូត្រមានន័យថា «មាត្រាដែលពោលពីធម្មជាតិដែលគ្មានក្តីចម្រើន ឬ ធម៌ជា ហេតុនាំឲ្យមាន ក្តីវិនាស»។ សូត្រនេះមាន នៅក្នុងគម្ពីរ សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគទី៥៤ ទំព័រទី៣៦។ ធម៌នេះយើងអាចអះអាងថា មិនមែនធ្វើឲ្យអ្នកស្តាប់បានដល់នូវក្តីវិនាសឡើយ ផ្ទុយទៅវិញធ្វើឲ្យអ្នកស្តាប់បានដឹងច្បាស់ពីមូលហេតុដែលនាំឲ្យ វិនាស ហើយឲ្យគេជៀសវាង ដើម្បីគេចឲ្យផុតពីក្តីវិនាសហើយ ប្រសិនបើគេមិនបានស្តាប់ធម៌នេះ គេអាចនឹងមិនដឹងពីហេតុដែលនាំឲ្យវិនាសហេតុនេះអាចនឹង ប្រព្រឹត្តខុសជាហេតុនាំឲ្យវិនាសទៅវិញទេ។ ក្នុងនោះព្រះពុទ្ធបានបង្រៀនពីហេតុផលសាមញ្ញៗ និងជាក់ស្តែងដូចជាថា បុគ្គលដែលមានវ័យចំណាស់ពេកហើយយកមនុស្សក្មេងជាប្រពន្ធប្តីភាពជា បុគ្គលអកត្តញ្ញូ មិនដឹងគុណឪពុកម្តាយ អ្នកលេងល្បែង ៣ប្រការ គឺល្បែងស្រី ល្បែងស្រា និងល្បែងភ្នាល់គ្រប់ប្រភេទ ភាពជាអ្នកខ្ជិលច្រអូសជាដើមថាហេតុនាំមកនូវក្តីវិនាស។

### ៣.៣. ការបោះបាយបិណ្ឌ

នៅព្រលឹមម៉ោង៤ព្រឹកប្រជាពលរដ្ឋតែងតែនាំគ្នាដើរទៅវត្តអារ៉ាមនានានៅក្នុងភូមិ ឬនៅក្បែរផ្ទះរបស់ខ្លួន ជាមួយនឹងនំចំណីដែលធ្វើរួចជាស្រេចដាក់ក្នុងចាន ឬស្បោងដើម្បីទៅវត្ត។ ការបោះបាយបិណ្ឌជាជំនឿអរូបិយមួយផងដែរ ដែលប្រជាពលរដ្ឋខ្មែរយើងនិយមធ្វើជារៀងរាល់ព្រឹក ដើម្បីបញ្ជូនឬឧទ្ទិសកុសលឱ្យទៅញាតិសន្តានសាច់សាលោហិតដែល បានចែកឋានទៅបរលោក។ ការបោះបាយបិណ្ឌ (**ការបោះដុំបាយ**) ជាសកម្មភាពមួយដែលមិនទាន់មានឯកភាពគ្នានៅក្នុងសង្គមពុទ្ធសាសនិក នៅឡើយ ដោយអ្នកខ្លះបានចាត់ទុកការបោះបិណ្ឌជាកិច្ចដ៏

សំខាន់មួយមិន អាចខានបាននៅក្នុងរដូវបុណ្យកាន់បិណ្ឌនេះ ខណៈដែលអ្នកខ្លះបានអះអាង និងរិះគន់ថា ការបោះបាយបិណ្ឌជាទង្វើមិនត្រឹមត្រូវ ជាភាពខ្ជះខ្ជាយ ជាការធ្វើមិនគោរពទានជាដើម។ អ្នក ដែលជឿថា បោះបាយបិណ្ឌមានប្រយោជន៍គិតថា បោះបាយបិណ្ឌគឺបោះឲ្យពួកប្រេត (ហេតុនេះទើបនៅតំបន់ខ្លះមិនហៅបាយបិណ្ឌទេ តែហៅថាបាយប្រេត)។ ចំណែកអ្នកពុទ្ធនិយមខ្លះទៀតបានអះអាងថា ការបោះបាយបិណ្ឌជាការធ្វើទានមិនត្រឹមត្រូវតាមការបង្រៀនរបស់ ព្រះពុទ្ធឡើយ។ទន្ទឹមនឹងនេះ ដែរពួកគេបានធ្វើការអធិដ្ឋានទៅដល់សាច់ញាត្តិ ដែលស្លាប់និងបោះបាយបិណ្ឌនៅជុំវិញព្រះវិហារ។ ជាពិសេស ពួកគេ ជឿ ថា វិញ្ញាណទាំងឡាយណាដែលគ្មាន សាច់ ញាត្តិត្រូវ បានគេ ដោះលែងពី ឋាននរកឲ្យមក កាន់វត្តអារាមដើម្បីទទួលអាហារពីសាច់ញាត្តិរបស់ពួកគេនៅពេលយប់។ វិញ្ញាណពួក គេត្រូវត្រឡប់ទៅឋាននរក វិញនៅមុនពេល ព្រះអាទិត្យរះ។ វិញ្ញាណអ្នកទាំងនោះគឺមាន ទំរង់ ធំ ហើយ ខ្ពស់ ដែល ពួកគេ អាច បោះ ជំហាន នៅ លើ ប្រាសាទ បាន។ ទោះជាយ៉ាងណាពួកគេមិនហានធ្វើដូច្នេះទេដោយខ្លាចថាពួកគេបានប្រព្រឹត្តអំពើបាបបន្ថែមទៀត។ពួកគេបានត្រឹមតែឈរយំហើយសុំអាហារ។ វិញ្ញាណទាំង នោះនឹងទៅគ្រប់៧វត្តដើម្បីរកមើលសាច់ញាត្តិ និង ទទួលអាហារពីពួកគេ។ ប្រសិនបើវិញ្ញាណទាំងនោះមិនឃើញសាច់ញាត្តិ របស់ពួកគេមក វត្តទេនោះ ពួកគេនឹងដាក់បណ្តាសាសាច់ញាត្តិរបស់ពួកគេ។នេះហើយជា មូលហេតុដែលសាច់ញាត្តិគួរតែយកចង្ហាន់ ទៅវត្តទោះ បីជាច្រើនឬក៏តិច ក៏ដោយក្នុង អំឡុងពេល បុណ្យភ្ជុំបិណ្ឌ។

## ៣.៤. ការពូនភ្នំខ្សាច់ក្នុងពិធីបុណ្យភ្ជុំបិណ្ឌ

ទាក់ទិននឹងជំនឿ ដែលពុទ្ធបរិស័ទលើកឡើងអំពីការពូនភ្នំខ្សាច់ នៅអំឡុងពេលបុណ្យភ្ជុំបិណ្ឌនេះ វាជាជំនឿមួយដែលខ្មែរយើងទូទៅយល់ថា វាល្អហើយមានប្រយោជន៍ទើបពួកគាត់ធ្វើ។ ហើយបានដាក់លុយទៅតាមភ្នំខ្សាច់នីមួយៗព្រមទាំងអុជធូបស្នាលា កំហុសបាបមួយចំនួនដែលខ្លួនបានសាងឡើង ដោយមិនបានចាប់អារម្មណ៍កន្លងមក។ ការពូនភ្នំខ្សាច់នេះក៏ជាការឧទ្ទិសកុសលមួយជូនដល់ឧបការីជនទាំងឡាយ ដែលបានលាចាកលោកផងដែរ។

### ៣.៥. ឧទ្ទិសផល និងសែន

គម្ពីរនានារបស់ពុទ្ធសាសនា ចែងថា មនុស្សដែលស្លាប់ទៅតែងទៅកើតក្នុងកំណើតនានា មនុស្សចិត្តអាក្រក់បានធ្វើបាបផ្សេង ៗ ដល់ស្លាប់ទៅតែងទៅកើតក្នុងកំណើត ១ហៅតាមភាសាបាលី ថា "បេត" ភាសាសំស្ក្រឹតថា " ប្រេត " ប្រែជាខ្មែរថា " ជនដែលធ្វើមរណកាលទៅកាន់បរលោក " ។

ពុទ្ធសាសនា កាលបើសំដែងដល់រឿងប្រេត ច្រើនស្រដៀងគ្នានឹងសាសនាព្រាហ្មណ៍ ដែលជាសាសនាចាស់របស់ប្រទេសឥណ្ឌា ព្រោះពុទ្ធសាសនា ជាសាសនាថ្មីកើតក្រោយសាសនាព្រាហ្មណ៍ គ្រាន់តែបំបែរតម្រែតម្រង់ឲ្យត្រឹមត្រូវឡើងតាមមតិរបស់ព្រះពុទ្ធ ប៉ុណ្ណោះ ។ គម្ពីរមហាវិភង្គ (អាទិកម្ម) ផ្នែកវិនយបិដក ត្រង់ចតុត្ថបារាជិកកណ្ឌ សំដែងពីប្រភេទរបស់ប្រេតថា មាន ១២ ពួក, គម្ពីរមិលិន្ទបញ្ហាបំព្រួញថា មាន ៤ ពួក គឺ ខុត្តូបជីវី ប្រេតចិញ្ចឹមជីវិតដោយមន្ទិលគក៏នឹងខ្នុះឈាម ១ ពួក ខុប្បបាសិកៈ ប្រេតស្រេកឃ្លានអាហារជានិច្ច ១ ពួក និជ្ឈាមតណ្ហិកៈ ប្រេតភ្លើងឆេះជានិច្ច ១ ពួក បរទត្តូបជីវី ប្រេតចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសឲ្យ ១ ពួក គឺពួកបរទត្តូបជីវីប្រេតនេះហើយ ដែលយើងតែងធ្វើបុណ្យកាន់បិណ្ឌ បុណ្យភ្ជុំបិណ្ឌ ឧទ្ទិសផល ឬសែនឲ្យ ។

របៀបឧទ្ទិសផល ពោលដោយសង្ខេប គឺយកបង្អែមចម្អាបដែលហៅថា "បិណ្ឌ" នោះទៅប្រគេនព្រះសង្ឃ វេរប្រគេនចំពោះព្រះសង្ឃហើយឧទ្ទិសផលដោយវាចាមានដើមថា " ផលទាននៃយើងខ្ញុំទាំងឡាយនេះ សូមឲ្យបានទៅដល់អ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើមដែលទោកាន់បរលោកហើយ " ។ ធ្វើបែបនេះរាល់ព្រឹក គ្រប់ថ្ងៃដាក់បិណ្ឌ នឹង ថ្ងៃភ្ជុំ ។

របៀបសែន ពោលដោយសង្ខេប គឺគេធ្វើតែម្តងក្នុងថ្ងៃបង្ហើយត្រង់វេលាយប់ថ្ងៃ ១៥ រោច ខែភទ្របទ ជាថ្ងៃភ្ជុំបិណ្ឌ ។ វេលាសែនបើជាទំនៀមរាស្ត្រ មហាជនគ្រប់ផ្ទះតែងរៀបក្រាលកន្ទេល កម្រាលមានខ្នើយ ១ ដាក់ក្បាលកន្ទេល មានសំពត់សពាសពីលើខ្នើយ មានផ្តិលទឹក ពានស្លា បារី តុ ថាស បង្អែម ចំអាប ឆ្នេង-ស្តាំ រួចម្តាយឪពុកប្រមូលបងប្អូនកូនចៅនៅក្នុងផ្ទះមកជួបជុំ ហើយ និយាយប្រតិស្ឋអទិស្ឋាន

ថា ″ សូមអញ្ជើញជីដូនជីតាពិសាក្រយាទាំងនេះឲ្យបរិបូណ៌ ″ ។

ទំនៀមព្រះរាជា ក៏មានលំនាំប្រហែលគ្នានឹងរាស្ត្រដែរ ប្លែកតែខាងព្រះរាជពិធីធ្វើនៅល្ងាចថ្ងៃ ១៤ រោច ដោយមានគ្រឿងប្រដាប់ល្អៗ នឹងហៅរបៀបសែននោះតាមរាជសព្ទថា ″ **ថ្វាយព្រះបិតរ** ″ ដូចបរិយាយក្នុងកំណត់ព្រះរាជពិធីថ្វាយព្រះបិតរខាងដើមមកហើយ នឹងមាននាម៉ឺនសព្វមុខមន្ត្រីគាល់ចាក់ទឹកដូងថ្វាយជាឧឡារិកអធិកអ ធំជាងរាស្ត្រប៉ុណ្ណោះ ។

## ៣.៦. ពិធីសែន

ពិធីសែននំចំណីឲ្យផ្ទាល់ទៅខ្មោច ឬ ប្រេត ជាពិធីខាងសាសនាព្រាហ្មណ៍ ។ ឯពុទ្ធសាសនាមិនមានពិធីដូច្នោះទេ មានតែពិធីប្រគេនទានចំពោះព្រះសង្ឃ ឬឲ្យទានដល់ឧបាសក អ្នកមានត្រៃសរណគមន៍ នឹងមានសីល ហើយបញ្ចេញវាចាឧទ្ទិសផលទៅ ដែលហៅតាមភាសាបាលី ″ ទក្ខិណានុប្បទាន ″ ប៉ុណ្ណោះ ។ ប៉ុន្តែស្រុកខ្មែរយើង តាំងពីសម័យបុរាណរហូតដល់សម័យបច្ចុប្បន្ន ទាំងព្រះរាជាទាំងប្រជារាស្ត្រ នៅវេលាដែលទ្រង់ធ្វើនឹងធ្វើបុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌ ដែលជាបុណ្យបញ្ជូនផលទៅដូនតានោះ តែងទ្រង់ធ្វើ នឹងធ្វើទានទាំង ២ បែប គឺទាំងពិធីប្រគេនទានចំពោះព្រះសង្ឃឧទ្ទិសផលទៅផង ទាំងពិធីសែនផង ។

ទំនៀមសែនដូនតា ជាទំនៀម ១ យ៉ាង ដែលពុទ្ធិកជនខេមរជាតិទូទៅទាំងប្រទេសកម្ពុជា ធ្លាប់ប្រព្រឹត្តជាយូរយារណាស់មកហើយតែទំនៀមនេះ ខេមរជនមិនមែនផ្តើមធ្វើខ្លួនឯងមុនគេបំផុតទេ គឺធ្វើតាមទំនៀមឥណ្ឌានៅប្រទេសឥណ្ឌៀ ដ្បិតប្រវត្តិសាស្ត្រខ្មែរពោលថា ″ ជាតិខ្មែរ មានពូជពង្សតមកពីប្រទេសឥណ្ឌៀ ព្រោះហេតុនេះទើបខ្មែរធ្វើបុណ្យកាន់បិណ្ឌ នឹងភ្ជុំបិណ្ឌមានធ្វើទាំងកិច្ចសែនផង ជាប់ជាប្រពៃណីទាំងព្រះរាជាទាំងប្រជារាស្ត្រ ដរាបមកដល់សម័យបច្ចុប្បន្ន ។

បុណ្យកាន់បិណ្ឌនឹងភ្ជុំបិណ្ឌ ក្នុងកម្ពុជរដ្ឋ ផ្តើមធ្វើពីក្នុងរជ្ជកាលណា ? ពុទ្ធសករាជប៉ុន្មាន ?បណ្តារឿងដើមពីកំណើតបុណ្យកាន់បិណ្ឌនឹងភ្ជុំបិណ្ឌ ក្នុងប្រទេសកម្ពុជានេះ ជាបញ្ហាលំបាកដោះស្រាយ មិនងាយនឹងសម្រេចឲ្យប្រាកដថា ផ្តើមធ្វើពីរជ្ជកាលណា ឬពុទ្ធសករាជប៉ុន្មាន ឲ្យប្រាកដបានទេ ដ្បិតពង្សាវតារក្រុងកម្ពុជា ពុំ

*មានចែងឲ្យច្បាស់ឡើយ ឃើញមានតែរាជពង្សាវតារមួយ ក្នុងរជ្ជកាលព្រះករុណាបរមកោដ្ឋ (* ***ព្រះអង្គឌួង ព.ស. ២៣៩១ – ២៤០៤ គ.ស. ១៨៤៨ – ១៨៥៩*** *) ឈ្មោះរាជពង្សាវតារក្រុងកម្ពុជា រជ្ជកាលព្រះបរមកោដ្ឋ អក្សរខ្មែរច្បាប់សរសេរដៃរបស់អ្នកឧកញ៉ាយោមរាជ ឈុន ដែលមានក្នុងបណ្ណាល័យ នៃពុទ្ធសាសនបណ្ឌិត្យលេខ គ.២៨ និយាយបន្តិចថា " ថ្ងៃ ១ រោច ខែភទ្របទ កាន់បិណ្ឌក្នុងព្រះរាជវាំង ថ្ងៃ ១៤ រោច ខែភទ្របទ ព្រះរាជាទ្រង់ចេញថ្វាយព្រះបិតរ ថ្ងៃ ១៥ រោច ខែភទ្របទ ទេសនាគាថាពាន់ " ប៉ុណ្ណោះ ។*

### ៣.៧. ប្រេត

*នៅក្នុងគម្ពីរព្រះត្រៃបិដកនៃពុទ្ធសាសនានិកាយថេរវាទ នៅក្នុងតាមគម្ពីរព្រះពុទ្ធសាសនាបានចែងថា មនុស្សដែលស្លាប់ទៅតែងទៅកើតទីផ្សេងៗតាមកម្មរបស់ខ្លួន។ មនុស្សចិត្តអាក្រក់ ដែលបានធ្វើបាបកម្មផ្សេងៗ លុះស្លាប់ទៅតែងតែកើតជាប្រេត ៤ប្រភេទ គឺប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម ប្រេតស្រេកឃ្លានអាហារជានិច្ច ប្រេតដែលភ្លើងឆេះជានិច្ច និងប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសទៅឱ្យ។ គេតែងនិយមជ្រើសរើសចំថ្ងៃរនោចខែភទ្របទ ព្រោះពេលវេលានោះព្រះចន្ទ ពុំសូវមានពន្លឺ ហើយចេះតែងងឹតទៅៗ ព្រោះឱកាសនោះហើយ ដែលយមរាជដោះលែងពួកប្រេតទាំងនោះឱ្យមករស់នៅលាយឡំជាមួយមនុស្សចាំទទួល ភោគផលដែលបងប្អូនញាតិសន្តាន ដែលញាតិឧទ្ទិសឱ្យ ព្រោះពួកប្រេតខ្លាចពន្លឺណាស់។ ប្រសិនបើរយៈពេល១៥ថ្ងៃ ពួកប្រេតដើររកគ្រប់វត្តពុំមានឃើញបងប្អូនញាតិសន្តានណាធ្វើបុណ្យ បញ្ជូនកុសលទៅឱ្យទេ ពួកគេនឹងអត់បាយអត់ទឹកស្រេកឃ្លានវេទនាយ៉ាងក្រៃលែង ហើយនឹងជេរប្រទេចផ្តាសាដល់បងប្អូនញាតិកាទាំងឡាយឱ្យហិនហោច ទ្រព្យសម្បត្តិព្រាត់ប្រាស់ឪពុកម្តាយ ប្តីប្រពន្ធ កូនចៅ ញាតិផៅទាំងប្រាំពីរសន្តាន។*

## ៤. សេចក្តីសន្និដ្ឋាន

### ៤.១. គុណសម្បត្តិ

មានអត្ថន័យធំធេងណាស់សម្រាប់ពុទ្ធបរិស័ទខ្មែរយើង ព្រោះថា បុណ្យភ្ជុំបិណ្ឌនេះធ្វើឡើងដើម្បីឧទ្ទិសថ្វាយដល់ វិញ្ញាណក្ខន្ធ បុព្វបុរស ញាតិកាទាំងប្រាំពីរសន្តានដែលបានចែកឋានទៅកើតជាប្រេត ទៅកើតក្នុងនរក ឬក៏សភាវៈផ្សេងៗ។ មួយវិញទៀតនោះបុណ្យភ្ជុំបិណ្ឌជាបុណ្យជួបជុំបងប្អូន ញាតិផៅគ្រប់ទិសទី សម្តែងនូវសេចក្តីសារទររីករាយ គ្រប់ៗគ្នា និងអ្វីដែលសំខាន់នោះ កាលណាមនុស្សយើងមានសទ្ធាជ្រះថ្លា ក្នុងព្រះធម៌ ក្នុងការធ្វើបុណ្យ ធ្វើទាននោះ វាជាបច្ច័យមួយជួយធ្វើឲ្យមនុស្សយើងមានចិត្តស្ងប់ រំលស់នូវភាពសៅហ្មង គ្រប់ៗគ្នា ហើយ វា ជា ប្រពៃណី មួយ សំរាប់ តំណាង នៅ ទំនៀមទំលាប់ នៃ ព្រះរាជាណាចក្រកម្ពុជា ទៀត ផង ហើយ សំរាប់ ឲ្យ ក្មេង ជំនាន់ ច្បាស់ ជា ថាដឹងនិងបានយល់នូវទំនៀមទំលាប់ប្រពៃណីខ្មែរ។

### ៤.២. គុណវិបត្តិ

ប៉ុន្តែផ្ទុយទៅវិញ "**ពិធីបុណ្យភ្ជុំបិណ្ឌ**" ដែលជាប្រពៃណីជាតិខ្មែរនេះ ក៏បានជះឥទ្ធិពលអវិជ្ជមានមួយចំនួនដល់សង្គមផងដែរ។ តាមការស្រាវជ្រាវបានឲ្យយើងសង្កេតឃើញថា ការបោះបាយបិណ្ឌ ដែលជាពិធីមួយក្នុង បុណ្យភ្ជុំបិណ្ឌ នេះ ធ្វើឲ្យខាតបង់នូវ ថវិកាមួយចំនួន ដែល ប្រជាពលរដ្ឋខ្មែរ ចំណាយ ទៅលើអង្ករដំណើប ជាវត្ថុធាតុដើម សម្រាប់ធ្វើបាយបិណ្ឌ ពោលគឺ យកអង្ករទៅចោលទទេៗ ហើយធ្វើឲ្យ ខូតបរិស្ថាន នៅជុំវិញព្រះវិហារ ក៏ដូចជាបរិស្ថាននានាជុំវិញវត្តគ្មានសណ្តាប់ធ្នាប់ ជុំបាយពាសវាលពាសកាល អាចបង្កជាក្លិនមិនល្អ ។

## ៥. ការវាយតម្លៃ

ជាចុងក្រោយ បន្ទាប់ពីបានធ្វើការបកស្រាយនូវអត្ថបទ "**ពិធីបុណ្យភ្ជុំបិណ្ឌ**" រួចមកយើងអ្នកសិក្សា អាចធ្វើការ វាយតម្លៃ ឬក៏ ដាក់តម្លៃឱ្យពិធីបុណ្យភ្ជុំបិណ្ឌនេះថា ជាបុណ្យប្រពៃណីជាតិ ដែលបង្ហាញឲ្យឃើញពីជំនឿ ក្នុងព្រះពុទ្ធសាសនា ។ ការគោរពស្រលាញ់អ្នកមានគុណ ដែលបានស្លាប់ ចែក ឋានដោយ មិនដឹងទៅកើតទីណាឲ្យប្រាកដ ហេតុនេះមានតែការធ្វើ បុណ្យ ឧទ្ទិសផល្លានិសង្សតាម

ព្រះសង្ឃដែលជាបុគ្គលមានសីល នោះទេ។

## ឯកសារយោង


១. *ភ្ជុំបិណ្ឌការបោះបាយបិណ្ឌ និងបរាភវសូត្រ*, អំពីស្រ្តី

២. *ភ្ជុំបិណ្ឌ ជាបុណ្យប្រវត្តិសាស្ត្ររបស់បុព្វជនខ្មែរ*, សុខភាពកម្ពុជា

៣. *ទស្សនាវដ្តីសុខភាពយើង*, លេខ០៣២

៤. *ព្រះរាជពិធីទ្វារទសមាស*, ភាគទី ២